00610792

D424/3/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០០៥)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: ខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ អបជ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ ជំទាស់នឹង ដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តសៀមរាប D424**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ |
| --- | --- |
| **សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | **អង្គបុរេជំនុំជម្រះ៖** |
| លោកស្រី ជេត វណ្ណលី | ចៅក្រម ប្រាក់ គឹមសាន |
| ផ្ញើជូន៖ | ចៅក្រម ន័យ ថុល |
| **សហព្រះរាជអាជ្ញា៖** | ចៅក្រម ហួត វុទ្ធី |
| លោកស្រី ជា លាង | ចៅក្រម Catherine MARCHI-UHEL |
| លោក Andrew T. CAYLEY | ចៅក្រម Rowan DOWNING |

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ស៊ិន សុវ៉ន លោក ហុង គីមសួន

លោកស្រី ម៉ុច សុវណ្ណារី លោក គីម ម៉េងឃី

លោក នី ចាន់ឌី លោក ឡោ ជុនធី

លោក គង់ ពិសី លោក យុង ផានិត

លោកស្រី Lyma NGUYEN

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Olivier BAHOUGNE

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

អ្នកស្រី Silke STUDZINSKY

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោក Emmanuel ALTIT

លោក Emmanuel JACOMY

លោក Barnabe NEKUIE

លោក Daniel LOSQ

លោក Julien RIVET

លោក Pascal Aubion

លោកស្រី Francoise GAUTRY

**សហមេធាវីការពារក្តីជនត្រូវចោទ៖**

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

**នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

00610794

# សំណើជាបន្ទាន់សុំបន្ថែមចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍

១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលមូលនិធិពីតុលាការមានបំណងដាក់បណ្តឹងឧទ្ធរណ៍សង្ខេបសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តសៀមរាប("បណ្តឹងឧទ្ធរណ៍") ដោយអនុលោមតាមវិធាន៧៧ ស្ទួន(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុង)។

២. បណ្តឹងឧទ្ធរណ៍នេះនឹងមានចំនួនប្រហែល១២០ទំព័រ ដោយមិនរាប់បញ្ចូលទំព័រចំណងជើង ទំព័រឯកសារយោង និងទំព័រឧបសម្ព័ន្ធនោះទេ។ ដូច្នេះ បណ្តឹងឧទ្ធរណ៍ទាំងនេះនឹងមានកម្រាស់លើសពី ៦០(ហុកសិប)ទំព័រ ដូចដែលបានកំណត់ជាភាសាខ្មែរ ដោយមាត្រា៥.២នៃ *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក.*។

៣. យើងខ្ញុំស្នើសុំឲ្យលោក-លោកស្រីចៅក្រមនៃអង្គបុរេជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៥.៤ នៃ *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក.*[១] ដើម្បីអនុញ្ញាតឲ្យមានការបន្ថែមចំនួនទំព័ររហូតដល់១២០ទំព័រ ដោយពិនិត្យលើកាលៈទេសៈពិសេសមួយចំនួន ដូចខាងក្រោមនេះ ៖

ក. បណ្តឹងឧទ្ធរណ៍ទាំងនេះ ពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលត្រូវបានបដិសេធក្នុងខេត្តសៀមរាបគឺចំនួន ១០៨នាក់ដែលជាកូនក្តីរបស់យើងខ្ញុំ។

ខ. ប្រសិនបើខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍រួមត្រូវបានកំហិតឲ្យមានកម្រាស់ត្រឹមតែចំនួន៦០ទំព័រនេះគឺជាការបង្ខំឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីកាត់បន្ថយខ្លឹមសារផ្នែកអង្គហេតុ និងអង្គច្បាប់យ៉ាងច្រើនដែលជាសំអាងនៃបណ្តឹងឧទ្ធរណ៍ ដូច្នេះវានឹងបណ្តាលឲ្យមានអយុត្តិធម៌ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

គ. ជៀសវាងការដាក់បណ្តឹងដោយបំបែកចេញពីគ្នា ដែលនាំឲ្យងាយស្រួលក្នុងការគ្រប់គ្រងឯកសារ និងការពិនិត្យលើពាក្យប្តឹង។

---

[១] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី ៤។

៤. ដើម្បីឆ្លើយតបទៅនឹងភាពបន្ទាន់ដែលតម្រូវឱ្យមានដោយរយៈពេលនៃបណ្តឹងឧទ្ធរណ៍ (១០ថ្ងៃបន្ទាប់ពីថ្ងៃពេលជូនដំណឹងគឺត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១០ដែលជាថ្ងៃចុងក្រោយ) មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះឆ្លើយតបយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបានទៅនឹងសំណើរបស់យើងខ្ញុំ ដូចបានជម្រាបជូនខាងលើ។

សូម **លោក-លោកស្រីចៅក្រម** មេត្តាទទួលយកសំណើសុំនេះដោយអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**ជេត វណ្ណលី**